# វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំសម្រាប់កុមារ
## អ្វីដែលមាតាបិតា/អាណាព្យាបាលគួរដឹង

**វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំត្រូវបានណែនាំឱ្យចាក់សម្រាប់កុមារអាយុ 6 ខែឡើងទៅ។**

### ហេតុអ្វីកុមារគួរតែចាក់វ៉ាក់សាំង?

នៅសហរដ្ឋអាមេរិក ជំងឺផ្តាសាយធំគឺជាដើមហេតុចម្បងនៃការស្លាប់ដោយសារជំងឺដែលអាចបង្ការដោយវ៉ាក់សាំង។ កុមារជាង 15 លាននាក់នៅសហរដ្ឋអាមេរិកបានឆ្លងជំងឺ COVID-19។ ទារកអាយុក្រោម 6 ខែមិនអាចចាក់វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំបានទេ ដូច្នេះប្រការសំខាន់គឺមនុស្សនៅជុំវិញខ្លួនទារកត្រូវចាក់វ៉ាក់សាំង។ សូម្បីទារកមានសុខភាពល្អក៏អាចឈឺធ្ងន់ដោយសារជំងឺ COVID-19 និងផ្តាសាយធំ ហើយអាចចម្លងជំងឺនេះទៅអ្នកផ្សេងទៀតទាំងមិនដឹងថាពួកគេឈឺ។

វ៉ាក់សាំងទាំងនេះជួយការពារកុំឱ្យឈឺធ្ងន់ធ្ងរ ចូលព្យាបាលក្នុងមន្ទីរពេទ្យ និងស្លាប់ដោយសារជំងឺ COVID-19 និងផ្តាសាយធំ។ វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំអាចចាក់ក្នុងពេលតែមួយបាន ដើម្បីឱ្យមានភាពងាយស្រួល និងដើម្បីការពារខ្លួនអ្នកប្រសើរបំផុតពីជំងឺទាំងនេះ។

### តើខ្ញុំអាចនាំកូនខ្ញុំទៅចាក់វ៉ាក់សាំងដោយរបៀបណា?

រដ្ឋវ៉ាស៊ីនតោនផ្តល់វ៉ាក់សាំងដែលបានណែនាំទាំងអស់ដោយឥតគិតថ្លៃសម្រាប់កុមាររហូតដល់អាយុ 18 ឆ្នាំ។ សូមសាកសួរគ្លីនិកទូទៅ ឬគ្លីនិកកុមាររបស់កូនអ្នក ថាតើទីនោះមានវ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំឬអត់។

គ្រួសារដែលមិនទាន់មានអ្នកផ្តល់សេវាថែទាំសុខភាពអាចហៅទៅខ្សែទូរសព្ទបន្ទាន់នៃរដ្ឋវ៉ាស៊ីនតោនរបស់ **Help Me Grow** (ជួយឱ្យខ្ញុំលូតលាស់) លេខ 1-800-322-2588 ឬចូលទៅកាន់ **ParentHelp123.org** ដើម្បីស្វែងរកអ្នកផ្តល់សេវាថែទាំសុខភាព គ្លីនិក ឬធនធានសុខភាពផ្សេងទៀត។ សេវាកម្មនេះគឺឥតគិតថ្លៃ និងមានផ្តល់ជូនជំនួយផ្នែកភាសា។

អ្នកក៏អាចចូលទៅកាន់ **Vaccines.gov** ដើម្បីមើលបញ្ជីទីកន្លែងនៅជិតអ្នកដែលមានវ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំ ដែលចាក់វ៉ាក់សាំងដល់កុមារផងដែរ។

### តើកូនរបស់ខ្ញុំត្រូវការប៉ុន្មានដូស?

#### ផ្តាសាយធំ៖

- ប្រសិនបើទារក ឬកូនរបស់អ្នកដែលមានអាយុក្រោម 8 ឆ្នាំកំពុងចាក់វ៉ាក់សាំងផ្តាសាយធំ *លើកទីមួយ* ពួកគេនឹងត្រូវការ 2 ដូសដោយចាក់មុនក្រោយគ្នា 1 ខែ។
- អ្នកដែលធ្លាប់ចាក់វ៉ាក់សាំងជំងឺផ្តាសាយធំកាលពីមុនត្រូវការតែ 1 ដូសប៉ុណ្ណោះ។

#### COVID-19៖

- កុមារអាយុ 6 ខែដល់ 4 ឆ្នាំចាក់វ៉ាក់សាំងស៊េរី Pfizer ដែលមាន 3 ដូស ឬវ៉ាក់សាំងស៊េរី Moderna ដែលមាន 2 ដូស។
- កុមារអាយុ 5 ឆ្នាំឡើងទៅចាក់តែ 1 ដូសនៃវ៉ាក់សាំង Pfizer ឬ Moderna។

  កុមារអាយុ 6 ខែឡើងទៅដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬធ្ងន់ធ្ងរគួរតែចាក់ស៊េរីដែលមាន 3 ដូស និងអាចចាក់ដូសបន្ថែមក្រោយពេលចាក់ដូសចុងក្រោយយ៉ាងតិច 2 ខែ។

*សាកសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកថាមានជម្រើសវ៉ាក់សាំងអ្វីខ្លះសម្រាប់ជំងឺ COVID-19 និងផ្តាសាយធំ និងជម្រើសណាល្អបំផុតសម្រាប់អ្នក និងគ្រួសាររបស់អ្នក។*



សម្រាប់សំណួរអំពីវ៉ាក់សាំងជំងឺ COVID-19៖

ចូលទៅកាន់៖ **VaccinateWA.org/kids**

ហៅទូរសព្ទទៅ៖ **1-833-VAX-HELP** (1-833-829-4357) រួចចុចសញ្ញា #

មានផ្តល់ជូនជំនួយផ្នែកភាសា។

flu free WASHINGTON

Vaccinate WA

CovidVaccineWA.org

# សំណួរចោទសួរជាញឹកញាប់៖ វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំ

## តើកូនរបស់ខ្ញុំត្រូវការចាក់វ៉ាក់សាំងថ្មីដែរទេ ប្រសិនបើគាត់ធ្លាប់ចាក់វ៉ាក់សាំងពីមុន?

ត្រូវការចាក់។ វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំត្រូវបានអាប់ដេតឱ្យត្រូវនឹងប្រភេទវីរុសដែលត្រូវបានរំពឹងថាកើតមានជាទូទៅបំផុតនៅរដូវកាលចម្លងវីរុសផ្លូវដង្ហើមនាពេលខាងមុខ។ វ៉ាក់សាំងមានប្រសិទ្ធភាពក៏ពិតមែន ប៉ុន្តែវាថមថយទៅតាមពេលវេលា។ ការចាក់វ៉ាក់សាំងឱ្យទាន់សភាពការណ៍នៅតែជាវិធីដ៏មានប្រសិទ្ធភាពបំផុតក្នុងការបន្តការពារពីជំងឺទាំងនេះ។ វាត្រូវការពេលប្រហែល 2 សប្តាហ៍ក្រោយចាក់វ៉ាក់សាំងទើបមានប្រព័ន្ធការពារ។

## តើវ៉ាក់សាំងមានសុវត្ថិភាពសម្រាប់កូនខ្ញុំដែរទេ?

មានសុវត្ថិភាព។ វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំត្រូវបានចាត់ទុកថាមានសុវត្ថិភាពណាស់សម្រាប់កុមារ។ គ្មានការរកឃើញថាមានផលប៉ះពាល់ធ្ងន់ធ្ងរទេនៅក្នុងការពិសោធវេជ្ជសាស្ត្រចំពោះវ៉ាក់សាំងជំងឺ COVID-19 លើយុវជន។ វ៉ាក់សាំងជំងឺផ្តាសាយធំត្រូវបានប្រើយ៉ាងមានសុវត្ថិភាពជាង 70 ឆ្នាំមកហើយ។ វ៉ាក់សាំងត្រូវបានធ្វើតេស្ត និងតាមដានជាបន្តបន្ទាប់ដើម្បីរក្សាសុវត្ថិភាព និងប្រសិទ្ធភាព។ ផលប៉ះពាល់ធ្ងន់ធ្ងរកម្រកើតមានខ្លាំងណាស់។ វ៉ាក់សាំងជំងឺ COVID-19 និងផ្តាសាយធំត្រូវបានណែនាំសម្រាប់អ្នកគ្រប់គ្នាដែលមានអាយុ 6 ខែឡើងទៅ។

## តើវ៉ាក់សាំងទាំងនេះមានផលប៉ះពាល់ជាទូទៅអ្វីខ្លះលើកុមារ?

ផលប៉ះពាល់ជាទូទៅបំផុតមានដូចជា ឈឺដៃ នឿយហត់ ឈឺក្បាល និងឈឺសាច់ដុំ។ ជាទូទៅ ផលប៉ះពាល់មានកម្រិតពីស្រាលទៅមធ្យម ហើយកើតឡើងក្នុងចន្លោះពេល 2 ថ្ងៃបន្ទាប់ពីចាក់វ៉ាក់សាំង ហើយជាធម្មតាបាត់ទៅវិញក្នុងចន្លោះពេល 1 ទៅ 2 ថ្ងៃ។ មានភស្តុតាងបង្ហាញពីការជាប់ទាក់ទងគ្នារវាងវ៉ាក់សាំងជំងឺ COVID-19 និងជំងឺរលាកសាច់ដុំបេះដូង/ជំងឺរលាកស្រោមបេះដូង ប៉ុន្តែវាជាករណីកម្រ និងជាទូទៅបង្កដោយការឆ្លងជំងឺ COVID-19។

ប្រសិនបើកុមារឆ្លងជំងឺ COVID-19 និង/ឬជំងឺផ្តាសាយធំ នោះហានិភ័យសុខភាពមានខ្ពស់ជាងខ្លាំងធៀបនឹងហានិភ័យនៃផលប៉ះពាល់ពីវ៉ាក់សាំង។ ផលប៉ះពាល់គឺជាសញ្ញាបញ្ជាក់ថា វ៉ាក់សាំងកំពុងមានប្រសិទ្ធភាព។ វ៉ាក់សាំងជំងឺ COVID-19 ឬផ្តាសាយធំមិនបង្កឱ្យមានជំងឺទេ។

## តើកុមារត្រូវយកអ្វីខ្លះទៅជាមួយសម្រាប់ការណាត់ជួប?

ក្នុងករណីភាគច្រើន មាតាបិតា និងអាណាព្យាបាលនឹងត្រូវផ្តល់ការយល់ព្រមឱ្យចាក់វ៉ាក់សាំងសម្រាប់អ្នកដែលមានអាយុក្រោម 18 ឆ្នាំ។ សាកសួរទីតាំងចាក់វ៉ាក់សាំងថាអ្នកត្រូវការអ្វីខ្លះដើម្បីផ្តល់ការយល់ព្រម។ កុំភ្លេចលើកឡើងផងដែរ ប្រសិនបើកូនរបស់អ្នកមានតម្រូវការពិសេស នៅពេលកំណត់ពេលណាត់ជួប។ វាអាចមានប្រយោជន៍ផងដែរក្នុងការយកវត្ថុសម្រាប់លួងកូនរបស់អ្នក ដូចជាប្រដាប់ក្មេងលេង ឬតុក្កតាជាដើម។

## ខ្ញុំមានសំណួរបន្ថែម។ តើខ្ញុំអាចទៅទីណា?

ស្វែងរកចម្លើយសម្រាប់សំណួរបន្ថែមនៅគេហទំព័រ **VaccinateWA.org/kids**។ អ្នកក៏អាចពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផងដែរ។

Washington State Department of HEALTH

**DOH 820-249 December 2023 Khmer**

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀក ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ doh.information@doh.wa.gov។